ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តបាត់ដំបង
សំណុំរឿងរដ្ឋប្បវេណី
លេខ ៨៤ ចុះថ្ងៃទី ១៤
ខែ មីនា ឆ្នាំ ២០០៦
សាលក្រម
លេខ ៨៦ ក ចុះថ្ងៃទី ០៥
ខែ មិថុនា ឆ្នាំ ២០០៦

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅទាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

ចៅក្រមជំនុំជំរះ

លោក [redacted] ជាប្រធានតុលាការខេត្តបាត់ដំបង

តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារងអមតុលាការខេត្តបាត់ដំបង

ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ៨៤ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦ ដែលមាន :

កម្មវត្ថុបណ្តឹង : ប្តឹងទារប្រាក់ដើមចំនួន ៥.៤០០ ( ប្រាំពាន់ប្រាំរយ) ដុល្លាអាមេរិក ។

-ទារការប្រាក់ ៣%ក្នុងមួយខែសំរាប់រយៈពេល ៣៧ខែ ។

-ស៊ីបអូសទ្រព្យសម្បត្តិលក់ឡាយឡុងយកប្រាក់សងអោយខ្លួនក្នុងករណីចុងចម្លើយគ្មានប្រាក់សង ។

នាពេលសវនាការដើមចោទបានប្តឹងសុំកែប្រែកម្មវត្ថុទារប្រាក់ដើមចំនួន ៥.៥០០ ដុល្លាអាមេរិកមកនៅត្រឹម ៥.០០០ដុល្លាអាមេរិក និង សុំដកនូវចំណែកបណ្តឹងទារការប្រាក់ពីចុងចម្លើយ ។

រវាងដើមចោទឈ្មោះ ជ ជណ ភេទប្រុស អាយុ ៦១ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីនៅផ្ទះ មានទីលំនៅសព្វថ្ងៃនៅភូមិចំការសំរោង២ ឃុំចំការសំរោង ស្រុក-ខេត្តបាត់ដំបង ឪពុកឈ្មោះ ជ ន (ស) ម្តាយឈ្មោះ ម ជ (ស) មានប្រពន្ធឈ្មោះ ខ ពស មានកូន ០២នាក់ ។

ដើមចោទឈ្មោះ ខ ពស ភេទស្រី អាយុ ៥៧ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ី.......មានទីលំនៅសព្វថ្ងៃនៅភូមិចំការសំរោង២ ឃុំចំការសំរោង ស្រុក-ខេត្តបាត់ដំបង ឪពុកឈ្មោះ ខ ឈ (ស) ម្តាយឈ្មោះ ៩.ឡ (ស) មានប្តីឈ្មោះ ជ ជណ មានកូន ០២នាក់ ។ មានឈ្មោះ ជ ជណ ជាតំណាង ។

ចុងចម្លើយឈ្មោះ ម ត ភេទប្រុស អាយុ ៥២ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ របររកស៊ីលក់ដូរ មានទីលំនៅ ភូមិចំការសំរោង២ ឃុំចំការសំរោង ស្រុក-ខេត្តបាត់ដំបង ឪពុកឈ្មោះ ម ហ (រ) ម្តាយឈ្មោះ លជ (ស) ប្រពន្ធឈ្មោះ ខ ខ មានកូន ០៥នាក់ ។

និង ចុងចម្លើយឈ្មោះ ខ ខ ភេទស្រី អាយុ ៥៥ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ របររកស៊ីលក់ដូរ មានទីលំនៅ ភូមិចំការសំរោង២ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោះ ខ ណា (ស) ម្តាយឈ្មោះ ច ម (ស) ប្តីឈ្មោះ ម ត ម្នានកូន ០៥នាក់ ។ មានឈ្មោះ ម ត ជាប្តីជាតំណាង ។

## ឯរឿងហេតុមានដូចតទៅ

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ឈ្មោះ ផ ផណា និង ពាក្យបណ្តឹងចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦ របស់ឈ្មោះ ខ ពស ប្តឹងទារប្រាក់ចំនួន ៥.៥០០ដុល្លាអាមេរិក ទារការប្រាក់៣%ក្នុងមួយខែ សំរាប់រយៈពេល ៣៧ខែពីឈ្មោះ ម ត និង ប្រពន្ធឈ្មោះ ខ ខ ដោយសំអាងហេតុថា កាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២ ឈ្មោះ ម ត និង ប្រពន្ធបានខ្ចីចងការប្រាក់ពីខ្លួនចំនួន ៥.៥០០ដុល្លាអាមេរិកព្រមព្រៀងអោយការប្រាក់ ៣%ក្នុងមួយខែសន្យាសងវិញ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ តាំងពីខ្ចីមកទើបសងការប្រាក់បាន ៥០០ដុល្លាអាមេរិក ក៏ឈប់សងរហូតពេលខ្លួនទៅទារចេះតែសន្យារហូតពុំសងខ្លួនសោះ ។ ក្នុងករណីអ្នកទាំងពីរគ្មានប្រាក់សងស៊ីបអូសទ្រព្យសម្បត្តិលក់ឡាយឡុងក្នុងករណីរឹងរូសសុំអោយដាក់គុកបង្ខំរូបកាយ ដើម្បីទារប្រាក់អោយខ្លួន ។

-បានឃើញរបាយការណ៍ជូនរឿងជំនុំជំរះលេខ ៨១១ ពសតរវ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៦ របស់ចៅក្រមស៊ើបសួរ ។

## នាពេលសវនាការ

-ឈ្មោះ ផ ផណា ជាដើមចោទបានឆ្លើយថា ខ្លួននៅតែប្តឹងទារប្រាក់ពីឈ្មោះ ម ត និង ប្រពន្ធឈ្មោះ ខ ខ តែពេលនេះខ្លួនសុំកែប្រែកម្មវត្ថុបណ្តឹង ដោយប្តឹងសុំទារតែប្រាក់ដើមចំនួន ៥.០០០( ប្រាំពាន់)ដុល្លាអាមេរិក ចំណែកការប្រាក់ខ្លួនឈប់ទាមទារហើយ ។ ប្រាក់ដែលខ្លួនប្តឹងទាមទារជាប្រាក់ ដែលចុងចម្លើយខ្ចីកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២ ដោយសុំខ្ចីបង្វិលតែមួយខែទេ តែដោយគាត់មិនបានសងក៏បង្វែរជាខ្ចីចងការប្រាក់វិញ ដោយបានធ្វើកិច្ចសន្យាជាលាយល័ក្ខអក្សរនៅភូមិ កាលពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២ ។ កាលខ្ចីដំបូងមានប្រាក់ដើមចំនួន ៥.៥០០ ( ប្រាំពាន់ប្រាំរយ) ដុល្លាអាមេរិក កំណត់ការប្រាក់៣%ក្នុងមួយខែ ។ តាំងពីខ្ចីមកចុងចម្លើយបានសងការប្រាក់បានចំនួន ១.៣២០( មួយពាន់បីរយម្ភៃ) ដុល្លាអាមេរិក បានសងប្រាក់ដើមចំនួន ៥០០( ប្រាំរយ )ដុល្លាអាមេរិក។ ប្រពន្ធខ្លួនក៏ប្តឹងទារប្រាក់ពីចុងចម្លើយដែរ គឺឯកភាពអោយចុងចម្លើយទាំងពីរនាក់ខ្ចីចងការ ។ ខ្លួនសំណូមពរទារប្រាក់ដើមគ្រប់ចំនួន ក្នុងករណីគ្មានប្រាក់សងសុំអោយតុលាការរឹបអូសទ្រព្យសម្បត្តិរបស់ចុងចម្លើយលក់ឡាយឡុងសងបំណុលអោយខ្លួន និង បើរឹងរូសសុំអោយតុលាការដាក់គុកបង្ខំដល់រូបកាយ ដើម្បីបង្ខំទារបំណុល ។

-ឈ្មោះ ម ត ជាចុងចម្លើយ និង ជាតំណាងចុងចម្លើយបានឆ្លើយថា ខ្លួន និង ប្រពន្ធខ្លួនឈ្មោះ ខ ខ ពិតជាបានខ្ចីចងការប្រាក់ពីដើមចោទប្រាកដមែន កាលពីឆ្នាំ ១៩៩៩ ដែលមានប្រាក់ដើមចំនួន ៧.០០០ ( ប្រាំពីរពាន់) ដុល្លាអាមេរិក ខ្លួនបានសងប្រាក់ដើមចំនួន ២.០០០ (ពីរពាន់)ដុល្លាអាមេរិក ការប្រាក់ខ្លួនបានសងអោយគាត់ដល់ឆ្នាំ ២០០២ ពេលខ្លួនគ្មានប្រាក់ដើមសងគាត់ គាត់អោយខ្លួន និង ប្រពន្ធធ្វើកិច្ចសន្យា ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២ ។ ពេលនេះខ្លួនព្រមសងប្រាក់ដើមអោយគាត់ចំនួន ៥.០០០( ប្រាំពាន់)ដុល្លាអាមេរិក តែខ្លួនសុំសងរំលោះក្នុងមួយខែ ១៥០ ( មួយរយហាសិប)ដុល្លាអាមេរិក រហូតដល់រួចបំណុល ដោយចាប់សងពីបំណាច់ខែ មិថុនា ឆ្នាំ ២០០៦ នេះតទៅ ។ ខ្លួនពុំព្រមទទួលយកតាមសំណូមពររបស់ដើមចោទទេ ខ្លួនមិនព្រមអោយតុលាការរឹបអូសទ្រព្យសម្បត្តិរបស់ខ្លួនលក់ឡាយឡុង ម៉ង មិនព្រមអោយដាក់គុកបង្ខំរូបកាយទេ ដោយមូលហេតុខ្លួនបានសង

ការប្រាក់លើសចំនួនប្រាក់ដើមហើយ ហើយខ្លួនក៏បានធានាសងគាត់ដែរ ។

-ឈ្មោះ ផ ផណ ជាដើមចោទបានឆ្លើយថា ខ្លួនពុំព្រមទទួលយកតាមការសុំសងរំលោះក្នុង ១ខែ១៥០ ដុល្លាអាមេរិកទេ ខ្លួនសុំទារទាំងស្រុង ។

## តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន

-ការប្តឹងទាមទារប្រាក់របស់ដើមចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់

-ការដោះសារសុំសងរំលោះរបស់ចុងចម្លើយមានលក្ខណៈផ្ទុយពីច្បាប់ ពុំអាចអោយតុលាការពិចារណាបានទេ ។

តាមមាត្រា៣,២២,៥៦ នៃក្រឹត្យច្បាប់លេខ ៣៨ក្រ.ច ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យាស្នើលោកចៅក្រមសំរេច និង ឯកភាព ។

-បានឃើញសេចក្តីផ្សះផ្សា

-បានស្តាប់ដើមចោទប្តឹងសុំ ឆ្លើយអោយការ សំអាងហេតុ

-បានស្តាប់ចម្លើយដោះសាររបស់ចុងចម្លើយឈ្មោះ ម ត

-បានស្តាប់ការសួរដេញដោលតទល់

-បានពិនិត្យកំណត់ហេតុ ឯកសារ ភស្តុតាងនានា

-បានស្តាប់យោបល់របស់តំណាងអយ្យការ

-បានពិចារណាត្រឹមត្រូវហើយ

## តុលាការខេត្តបាត់ដំបង
## យល់ឃើញថា

-បណ្តឹងចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ឈ្មោះ **ផ ផណ** ប្តឹងទារប្រាក់ដើមចំនួន ៥.០០០ដុល្លា ពីឈ្មោះ **ម ត** និង ឈ្មោះ **ខ ខ** ធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-បណ្តឹងចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦ របស់ឈ្មោះ **ខ ពស** ប្តឹងទារប្រាក់ដើមចំនួន ៥.០០០ដុល្លា ពីឈ្មោះ **ម ត** និង ឈ្មោះ **ខ ខ** ធ្វើឡើងត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-នាពេលសវនាការឈ្មោះ **ផ ផណ** និង តំណាងអោយដើមចោទឈ្មោះ **ខ ពស** ប្តឹងសុំដកនូវចំណែកបណ្តឹងទារការប្រាក់តាមកំណត់ច្បាប់ក្នុងរយៈពេល ៣៧ខែ ពីឈ្មោះ **ម ត** និង ឈ្មោះ **ខ ខ** ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ។

-លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦ របស់ឈ្មោះ **ខ ពស** ផ្ទេរសិទ្ធិអោយឈ្មោះ **ផ ផណ** ជាប្តីដើរក្តីជំនួសខ្លួន ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ។

-ពាក្យសុំផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ របស់ឈ្មោះ **ខ ខ** ផ្ទេរសិទ្ធិអោយឈ្មោះ **ម ត** ជាប្តីដើរក្តីជំនួសខ្លួនធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ច្បាប់ ។

-ឈ្មោះ **ម ត** និង ឈ្មោះ **ខ ខ** ពិតជានៅជំពាក់បំណុលឈ្មោះ **ផ ផណ** និង ឈ្មោះ **ខ ពស** ជាដើមចោទនូវប្រាក់ដើមចំនួន ៥.០០០ដុល្លាអាមេរិកប្រាកដមែន តាមកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២ ។

-ក្នុងការប្តឹងទារប្រាក់ពីចុងចម្លើយ ដើមចោទបានសំអាងលើកិច្ចសន្យាខ្ចីចងការប្រាក់ ដែលធ្វើឡើងរវាងខ្លួន ប្រពន្ធខ្លួន និង ចុងចម្លើយទាំងពីរនាក់ប្តីប្រពន្ធ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២ ជាភស្តុតាងអាចអោយតុលាការជឿបាន ពីព្រោះមានភស្តុតាងបន្ទាល់ជាឯកសារលាយល័ក្ខអក្សរច្បាស់លាស់ ហើយចុងចម្លើយក៏បានទទួលស្គាល់ដែរ ។

-កិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២ ដែលធ្វើឡើងរវាងគូភាគី ធ្វើឡើងមានសុពលភាព និង បានត្រឹមត្រូវតាមទម្រង់នៃកិច្ចសន្យាខ្ចីចងការប្រាក់ ។

-សំណូមពររបស់ដើមចោទប្តឹងសុំអោយតុលាការ សំរេចរឹបអូសទ្រព្យសម្បត្តិរបស់ចុងចម្លើយលក់ឡាយឡុងយកប្រាក់សងបំណុលអោយខ្លួន ក្នុងករណីចុងចម្លើយគ្មានប្រាក់សង និង ក្នុងករណីចុងចម្លើយរឹងរូសសុំឱ្យតុលាការសំរេចដាក់គុកបង្ខំដល់រូបកាយចុងចម្លើយទាំងពីរនាក់ ដើម្បីបង្ខំទារបំណុលអោយខ្លួនធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-សំណូមពររបស់ដើមចោទខាងលើនេះ ចុងចម្លើយឈ្មោះ ម ត និង ជាតំណាងអោយចុងចម្លើយឈ្មោះ ខ ខ មិនយល់ព្រមជាខុសច្បាប់ ពីព្រោះវាមានបញ្ញត្តិជាស្រេចក្នុងច្បាប់ជាធរមាន ។

-ឈ្មោះ ម ត និង តំណាងអោយចុងចម្លើយឈ្មោះ ខ ខ បានទទួលស្គាល់ថា ខ្លួន និង ប្រពន្ធរបស់ខ្លួនពិតជាបានខ្ចីចងការប្រាក់ពីដើមចោទ និង នៅជំពាក់ប្រាក់ដើមចំនួន ៥.០០០ដុល្លាអាមេរិកប្រាកដមែន ។ ជាចម្លើយដោះសារហុចប្រយោជន៍ទៅដើមចោទទាំងស្រុង ។

-ឈ្មោះ ម ត និង ជាតំណាងអោយចុងចម្លើយឈ្មោះ ខ ខ បានសុំសងប្រាក់ទៅដើមចោទ ដោយសុំសងរំលោះតាមខែ ក្នុង១ខែ១ចំនួន១៥០ដុល្លាអាមេរិក រហូតដល់រួចបំណុលធ្វើឡើងខុស និង គតិច្បាប់ ។

-ចុងចម្លើយជាភាគីមានកំហុស ដូច្នេះគាត់ត្រូវទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

## ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី

១-ក-ទទួលបណ្តឹងចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ឈ្មោះ ជ ជត ប្តឹងទារប្រាក់ដើមចំនួន ៥.០០០ ដុល្លាពីឈ្មោះ ម ត និង ឈ្មោះ ខ ខ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

ខ- ទទួលបណ្តឹង ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦ របស់ឈ្មោះ ខ សព ប្តឹងទារប្រាក់ដើមចំនួន ៥.០០០ដុល្លា ពីឈ្មោះ ម ត និង ឈ្មោះ ខ ខ ធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

គ-ទទួលលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦ របស់ឈ្មោះ ខ ពស ផ្ទេរសិទ្ធិអោយឈ្មោះ ជ ជណ ជាប្តីដើរក្តីជំនួសខ្លួនទុកជាត្រឹមត្រូវតាមច្បាប់ ។

ឃ-ទទួលពាក្យសុំផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ របស់ឈ្មោះ ខ ខ ផ្ទេរសិទ្ធិអោយឈ្មោះ ម ត ជាប្តីដើរក្តីជំនួសខ្លួនទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

ង-ទទួលសំណូមពររបស់ដើមចោទ ប្តឹងសុំអោយតុលាការសំរេចរឹបអូសទ្រព្យសម្បត្តិរបស់ចុងចម្លើយលក់ឡាយឡុងយកប្រាក់សងសំណុលអោយខ្លួន ក្នុងករណីចុងចម្លើយគ្មានប្រាក់សង និង ក្នុងករណីចុងចម្លើយរឹងរូសសុំអោយតុលាការសំរេចដាក់គុកបង្ខំដល់រូបកាយ ដើម្បីបង្ខំទារបំណុលអោយខ្លួនទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

ច-បដិសេធជាអសារសូន្យនូវសំណូមពររបស់ឈ្មោះ ម ត និង ជាតំណាងអោយចុងចម្លើយឈ្មោះ ខ ខ ប្តឹងសុំសងបំណុលរំលោះទៅអោយដើមចោទក្នុងមួយខែៗចំនួន ១៥០ដុល្លាអាមេរិក ដោយខុស និង គតិច្បាប់ ។

២-អោយឈ្មោះ ម ត និង ឈ្មោះ ខ ខ សងបំណុលអោយទៅឈ្មោះ ផ ផណ និង ឈ្មោះ ខ ពស នូវប្រាក់ដើមចំនួន ៥.០០០ ( ប្រាំពាន់) ដុល្លាអាមេរិចគត់ ។

-ក្នុងករណីឈ្មោះ ម ត និង ឈ្មោះ ខ ល គ្មានប្រាក់សងបំណុលអោយទៅដើមចោទត្រូវរឹបអូសទ្រព្យសម្បត្តិសាមីចុងចម្លើយទាំងពីរនាក់ លក់ឡាយឡុងយកប្រាក់សងអោយទៅឈ្មោះ ផ ផណ និង ឈ្មោះ ខ ពស ជាដើមបំណុល ។

-ក្នុងករណីចុងចម្លើយឈ្មោះ ម ត និង ឈ្មោះ ខ ខ រឹងរូសមិនព្រមសងបំណុលអោយទៅដើមចោទ ត្រូវដាក់គុកបង្ខំដល់រូបកាយ ដើម្បីបង្ខំទារបំណុលអោយទៅដើមបំណុលឈ្មោះ ផ ផណ និង ឈ្មោះ ខ ពស ។

-តាមបទបញ្ញត្តិមាត្រា៣.៤.២២.៥៦.៥៧.៥៩ នៃក្រឹត្យច្បាប់លេខ ៣៨ក្រ.ច ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

-តាមបទបញ្ញត្តិមាត្រា១.១២៥.១២៦.១២៧.១២៨ និង ១៣៣ នៃច្បាប់ស្តីពីវិធីអនុវត្តសាលាក្រមរដ្ឋប្បវេណី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ៥១ក្រ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៩៣ ។

៣-អោយឈ្មោះ ម ត និង ឈ្មោះ ខ ខ បង់ប្រាក់ប្រដាប់ក្តីចំនួន ៧.០០០រ០០ ប្រាក់នេះចំរែកបង់ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ១.៨០០រ០០ ចំណាយវង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០រ០០ ចំណាយក្នុងកិច្ចស៊ើបសួរចំនួន ៥.០០០រ០០ ។ ប្រាក់នេះបានកាត់យកពីប្រាក់ចំនួន ៧.០០០រ០០ ដែលដើមចោទបានបង់ទុកមុនរួចហើយ កាលបើសាលក្រមនេះចូលជាស្ថាពរអោយឈ្មោះ ម ត និង ឈ្មោះ ខ ខ សងប្រាក់ ៧.០០០រ០០ អោយទៅដើមចោទវិញ ។ និង អោយឈ្មោះ ម ត និង ឈ្មោះ ខ ខ បង់ពន្ធសមាមាត្រគិតជាប្រាក់រៀលស្មើនឹង ៥០ដុល្លាអាមេរិក ។

តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

៤-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះដើមចោទឈ្មោះ ផ ផណ និង តំណាងអោយដើមចោទឈ្មោះ ខ ពស និង ចុងចម្លើយឈ្មោះ ម ត និង ជាតំណាងអោយចុងចម្លើយឈ្មោះ ខ ខ ។ បើកផ្លូវប្តឹងឧទ្ធរណ៍ កំណត់រយៈពេល ០២ខែគិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជំរះ** |
| [redacted] | [redacted] |

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលក្រម អោយបានសំរេចតាមសាលក្រមនេះ និង អោយអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ ជួយអនុវត្ត បើមានសំណូមពរត្រឹមត្រូវពោលគឺ ។

បាត់ដំបង, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៦

ជ.ក្រឡាបញ្ជីសវនាការ

[redacted]

បានឃើញ

បាត់ដំបង, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៦

ប្រធានតុលាការខេត្ត

[redacted]